# រោគរលាកស្រោមខួរក្បាល
# **Meningitis**

រោគរលាកស្រោមខួរក្បាល ឬអ្នកខ្លះច្រើនហៅថា រោគរលាកខួរក្បាល ជារោគម្យ៉ាងដែលធ្វើឲ្យខូចទឹកស្រោបជុំវិញខួរក្បាល, ទឹកឆ្អឹងខ្នង, និងគំរោងឆ្អឹងខ្នង។

មូលហេតុដែលធ្វើឲ្យមានរលាកស្រោមខួរក្បាល គឺបណ្តាលមកពីមេរោគបាក់តេរី និងមេរោគវ៉ៃរើស។ ដើម្បីឲ្យដឹងថាមានរោគនេះ គ្រូពេទ្យត្រូវចាក់យកទឹកពីឆ្អឹងខ្នងរបស់អ្នកជម្ងឺបន្តិចទៅពិនិត្យមើល ហើយនិងបញ្ជាក់ឲ្យដឹងច្បាស់ថាមេរោគណាមួយ។

មេរោគបាក់តេរីដែលបណ្តាលឲ្យកើតរោគរលាកស្រោមខួរក្បាលមានបីយ៉ាង គឺ៖ មេរោគ Neisseria meningitidis, មេរោគ Haemophilus influenzae ប្រភេទ b, និង មេរោគ Streptococcus pneumoniae ។

មេរោគ Neisseria meningitidis, ច្រើនកើតនៅចំពោះក្មេងនិងមនុស្សចាស់ជរា ប៉ុន្តែ ពុំមែនបានន័យថា វាមិនអាចកើតចំពោះមនុស្សគ្រប់វ័យឡើយ។ មនុស្សប្រហែលជា ពី 5–20% មានដែលមេរោគនេះនៅក្នុងបំពងក តែពុំធ្លាក់ខ្លួនឈឺអ្វីឡើយ។ មេរោគនេះ ច្រើនឆ្លងតាមទឹកមាត់នៅពេលថើបគ្នា, ឬទទួលទានម្ហូបអាហារ, ទឹក, និងបារីជាមួយគ្នា។ ម្យ៉ាងទៀតមេរោគនេះក៏អាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន ដោយសារការកណ្តាសនិងក្អកដែរ។ អ្នកដែលប៉ះពាល់នឹងទឹកមាត់របស់អ្នកជម្ងឺគួរតែប្រើថ្នាំផ្សះ Antibiotic សំរាប់ការពារក្រែងលោធ្លាក់ខ្លួនឈឺ។

មេរោគ Haemophilus influenzae ប្រភេទ b ជួនកាលហៅថា Hib ក៏អាចបណ្តាលឲ្យកើតរោគរលាកស្រោមខួរក្បាលដែរ។ មនុស្សចាស់ភាគច្រើនមានការសំទៅនឹងមេរោគប្រភេទនេះ។ ជាសំណាងល្អដែលមានថ្នាំសំរាប់ចាក់ការពាររោគនេះ ដល់ទារកនិងក្មេងតូចដែលមានអាយុក្រោម 5 ឆ្នាំ។ អ្នកខ្លះដែលប៉ះពាល់នឹងទឹកមាត់របស់អ្នកជម្ងឺក៏គួរប្រើថ្នាំផ្សះ Antibiotic សំរាប់ការពារក្រែងលោធ្លាក់ខ្លួនឈឺដែរ។

មេរោគ Streptococcus pneumoniae ច្រើនមាននៅក្នុងបំពង់ករបស់អ្នកជម្ងឺ។ មនុស្សភាគច្រើនដែលមានមេរោគនេះច្រើនតែនៅមានសុខភាពល្អ។ ប៉ុន្តែ ចំពោះអ្នកដែលមានសុខភាពពុំសូវមាំមួន ហើយមានលក្ខណពុំធន់នឹងជម្ងឺផ្សេងៗ និងក្មេងតូច ឬជនចាស់ជរា អាចឆ្លងរោគ

នេះបានយ៉ាងឆាប់រហ័ស។ អ្នកជម្ងឺដែលមានមេរោគ Streptococcus pneumoniae ពុំចម្លងទៅអ្នកដទៃឡើយ។ អ្នកដែលប៉ះពាល់ទឹកមាត់របស់អ្នកជម្ងឺប្រភេទនេះ ពុំបាច់ប្រើថ្នាំផ្សះ Antibiotic សំរាប់ការពាទេ។

រោគរលាកស្រោមខួរក្បាលក៏អាចបណ្តាលមកពីមេរោគបាក់តេរីដទៃទៀតបានដែរ ប៉ុន្តែគេមានជំនឿថា រោគរលាកស្រោមខួរក្បាលដែលបណ្តាលមកពីមេរោគទាំងនោះ ពុំសូវធ្វើឲ្យឆ្លងឡើយ។

ចំណែកឯ រោគរលាកស្រោមខួរក្បាល ដែលបណ្តាលមកពីមេរោគវ៉ៃរើសវិញ អាចមានច្រើនជាងមេរោគបាក់តេរី។ មេរោគវ៉ៃរើសដែលធ្វើឲ្យកើតរោគរលាកស្រោមខួរក្បាលច្រើនជាងគេហៅថា មេរោគ Enteroviruses ។ គេរកឃើញមេរោគវ៉ៃរើសដែលឆ្លងរោគនេះ ច្រើននៅតាមបំពង់និងលាមករបស់អ្នកជម្ងឺ។ មេរោគនេះ អាចឆ្លងដោយសារការប៉ះដៃអ្នកជម្ងឺ និងប៉ះពាល់គ្នាទៅវិញទៅមក ជាពិសេស ចំពោះអ្នកដែលនៅផ្ទះក្នុងគ្រួសារជាមួយគ្នា។

មេរោគនេះ ជួនកាល ពុំធ្វើឲ្យមនុស្សធ្លាក់ខ្លួនឈឺទេ គឺវាគ្រាន់តែធ្វើឲ្យអ្នកនោះ ក្អួតឬរាគរុះប៉ុណ្ណោះ។ ភាគច្រើន មេរោគនេះ ច្រើនឆ្លងនៅពេលចុងរដូវ ក្តៅនិងដើមរដូវស្លឹកឈើជ្រុះ។ អ្នកជម្ងឺដែលធ្លាក់ខ្លួនឈឺដោយសារមេរោគវ៉ៃរើស ច្រើនពុំឈឺ ធ្ងន់ដូចជាអ្នកដែលឈឺ ដោយសារមេរោគបាក់តេរីទេ ហើយច្រើនជាវិញដោយឯងៗបាន។ អ្នកជម្ងឺប្រភេទនេះពុំបាច់ត្រូវការប្រើថ្នាំផ្សះ Antibiotic ឡើយ។

អាការៈរោគនៃរោគរលាកស្រោមខួរក្បាលគឺ គ្រុនក្តៅ និងឈឺក្បាល, ឈឺនិងរឹងកញ្ចឹងក, ក្អួតចង្អោរ, និងរមាស់។ អាការៈទាំងនេះអាចមានមួយរំពេច បន្ទាប់ពីអ្នកជម្ងឺកើតរោគភ្លាម។ អាការៈរោគសំខាន់ ម្យ៉ាងទៀតដែលគួរឲ្យកត់សំគាល់គឺ៖ ការផ្លាស់ប្តូរឥរិយាបថ ដូចជា វង្វេងស្មារតី, ឬផ្លាស់ប្តូរការទទួលទានដំណេក ដូចជាក្រភ្ញាក់ជាដើម។ ចំពោះក្មេងតូចៗខ្លះ គេអាច សង្កេតឃើញ ក្មេងនោះមានការមួរម៉ៅ, អស់កម្លាំងល្ហិតល្ហៃទន់ដៃជើង ឬពុំទទួលទានចំណីអាហារ។ ឯចំណែកទារកវិញ វាច្រើនមានការគ្រុនក្តៅ ប៉ុន្តែនេះពុំមែនជាអាការ;រោគតែមួយប៉ុណ្ណោះទេ។ អ្នកដែលមានអាការៈរោគទាំងនេះគួរអញ្ជើញទៅឲ្យគ្រូពេទ្យពិនិត្យមើលឲ្យបានច្បាស់លាស់។

មេរោគវ៉ៃរើសច្រើនឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដោយសារ ទឹកមាត់ឬលាមក។ ឯមេរោគបាក់តេរីវិញ ច្រើនឆ្លងដោយសារការប៉ះនឹងទឹកមាត់របស់អ្នកជម្ងឺ។ អ្នកខ្លះប្រហែលជាមានការសំនឹងមេរោគទាំងនេះតាំងពីកំណើតម្លេះ។

ដើម្បីការពារនឹងមេរោគរលាកស្រោមខួរក្បាល លោកអ្នកគួរលាងដៃនិងទឹកសាប៊ូឲ្យបាន ញឹកញាប់។ ការលាងដៃនេះ គឺដើម្បីការពារកុំឲ្យមេរោគឆ្លង ពីម្នាក់ទៅម្នាក់ទៀត។ ការកុំ ទទួលទានអាហារ, ទឹក, ឬប្រើសមស្លាបព្រាជាមួយគ្នា ក៏អាចការពារកុំឲ្យមានឆ្លងមេរោគនេះ បានដែរ។ បើសិនជាមានការប៉ះពាល់នឹងទឹកមាត់អ្នកជម្ងឺរលាកស្រោមខួរក្បាល គួរផ្តល់ ដំណឹងនេះទៅ ភ្នាក់ងារសុខាភិបាលប្រចាំតំបន់លោកអ្នក ឬទៅជួបគ្រូពេទ្យ ដើម្បីឲ្យគាត់ ចេញថ្នាំ Antibiotic សំរាប់លេបភ្លាម។

ក្នុងពេលបច្ចុប្បន្ននេះ មានថ្នាំចាក់ការពារចំនួន 5 ប្រភេទ សំរាប់ចាក់ការពារកុំឲ្យកើតរោគ រលាកស្រោមខួរក្បាលដល់ទារកពីអាយុ 2 ខែ ទៅទល់នឹងមនុស្សចាស់ជរាដែលមានសុខភាព ពុំសូវបរិបូរណ៍។ ថ្នាំចាក់ ការពារ ម្យ៉ាងទៀតហៅថា Meningococcal ។ ថ្នាំនេះសំរាប់ចាក់ ការពារ នៅពេលត្រូវការធ្វើ ដំណើរទៅតំបន់ណា ដែលមានកើតរោគរលាកស្រោមខួរក្បាល ច្រើន និងសំរាប់ចាក់ការពា អ្នកដែលពុំសូវមានសុខភាពបរិបូរណ៍។ ជាបន្ថែម ថ្នាំនេះក៏សំរាប់ ចាក់ឲ្យនិសិត្សដែលត្រូវ ចូលសិក្សានៅមហាវិទ្យាល័យឆ្នាំដំបូងដែរ។ និសិត្សឬឪពុកម្តាយ របស់និសិត្សទាំងនោះ គួរពិគ្រោះជាមួយគ្រូពេទ្យ ប្រចាំគ្រួសាររបស់ខ្លួនអំពីថ្នាំប្រភេទនេះ។

ចំពោះពត៌មានបន្ថែម សូមមេត្តាពិភាក្សាជាមួយវេជ្ជបណ្ឌិត ឬគ្រូពេទ្យរបស់លោកអ្នក ឬភ្នាក់ ងារសុខាភិបាលប្រចាំតំបន់លោកអ្នកផ្ទាល់។ ចំពោះលោកអ្នកនៅក្នុងទីក្រុងឡូវែល ទូរស័ព្ទ របស់ក្រសួងសុខាភិបាលគឺ 978-970-4010 ។ ម្យ៉ាងទៀត លោកអ្នកក៏អាចទូរស័ព្ទទៅ ក្រសួង សាធារណៈសុខាភិបាលប្រចាំរដ្ឋម៉ាស្សាឈូសេត ផ្នែកជម្ងឺឆ្លងនិងថ្នាក់ចាក់បង្ការរោគ ដោយ ចុចលេខ (617) 983-6800។

*ពត៌មាននេះដកស្រង់នឹងបកប្រែចេញពីពត៌មាននៃក្រសួងសាធារណៈសុខាភិបាលប្រចាំ រដ្ឋម៉ាស្សាឈូសេត ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។*